**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១០៧ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ត្រួតពិនិត្យផលិតផលថ្នាំជក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៤ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ដែលសរសេរជាអក្សរកាត់ថា "**គ.ត.ផ.ថ.**" ដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល ដើម្បីអប់រំនិងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់។

## ជំពូកទី២

## សមាសភាព

**មាត្រា២ .-**

គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ "**គ.ត.ផ.ថ.**" មានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសុខាភិបាល | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងសុខាភិបាល ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ១រូប | អនុប្រធាន |
| ៤. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ១រូប | អនុប្រធាន |
| ៥. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងព័ត៌មាន ១រូប | អនុប្រធាន |
| ៦. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ១រូប | សមាជិក |
| ៧. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ ១រូប | សមាជិក |
| ៨. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ១រូប | សមាជិក |
| ៩. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា ១រូប | សមាជិក |
| ១០. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ១រូប | សមាជិក |
| ១១. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប | សមាជិក |
| ១២. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម ១រូប | សមាជិក |
| ១៣. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ១រូប | សមាជិក |
| ១៤. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ១រូប | សមាជិក |
| ១៥. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី ១រូប | សមាជិក |
| ១៦. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ១រូប | សមាជិក |
| ១៧. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ១រូប | សមាជិក |
| ១៨. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងផែនការ ១រូប | សមាជិក |
| ១៩. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១រូប | សមាជិក |
| ២០. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល ១រូប | សមាជិក |
| ២១. រដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ១រូប | សមាជិក |
| ២២. តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ១រូប | សមាជិក |
| ២៣. អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ១រូប | សមាជិក |

២៤. ប្រធានមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព ១រូប សមាជិក និងលេខាធិការ

សមាសភាពជាក់ស្តែងរបស់ **គ.ត.ផ.ថ.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣ .-**

សមាជិក **គ.ត.ផ.ថ.** ជាបុគ្គលដែលមិនជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍ជាមួយឧស្សាហកម្មឬក្រុមហ៊ុនផលិតផលថ្នាំជក់ មានជាអាទិ៍ សមាជិកភាគហ៊ុនឬសមាជិកទទួលផលប្រយោជន៍ពីឧស្សាហកម្មឬក្រុមហ៊ុនផលិតផលថ្នាំជក់។

## ជំពូកទី៣
## ភារកិច្ចរបស់ គ.ត.ផ.ថ.

**មាត្រា៤ .-**

គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ "**គ.ត.ផ.ថ.**" មានភារកិច្ចដូចតទៅ៖

១. ពិនិត្យនិងផ្តល់យោបល់លើគោលនយោបាយ ផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិសម្រាប់ត្រួតពិនិត្យផលិតផលថ្នាំជក់ ដើម្បីសុខភាពនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

២. ពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ វិសោធនកម្មច្បាប់ អនុក្រឹត្យ សារាចរ សេចក្តីណែនាំ និងបទដ្ឋាននានា ទាក់ទងនឹងការត្រួតពិនិត្យផលិតផលថ្នាំជក់។

៣. ផ្សព្វផ្សាយ អប់រំ និងចលនាការចូលរួមពីគ្រប់មជ្ឈដ្ឋានលើការត្រួតពិនិត្យផលិតផលថ្នាំជក់ និងជំរុញឲ្យមានការចូលរួមពីស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សេវាឯកជន និងសហគមន៍ ដើម្បីអនុវត្តច្បាប់ អនុក្រឹត្យ សារាចរណែនាំ និងការស្រាវជ្រាវ សម្រាប់ការត្រួតពិនិត្យផលិតផលថ្នាំជក់ឲ្យមានប្រសិទ្ធភាព។

៤. សហការ តាមដាន និងពង្រឹងការអនុវត្តបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធ និងវាយតម្លៃផែនការ សកម្មភាព និងយុទ្ធសាស្ត្រជាតិស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់។

៥. សម្របសម្រួលការអង្កេតស្រាវជ្រាវលើការប្រើប្រាស់ផលិតផលថ្នាំជក់និងផលវិបាកនៃការប្រើប្រាស់ផលិតផលថ្នាំជក់លើសុខភាពនិងសេដ្ឋកិច្ច។

៦. សម្របសម្រួលលើការសិក្សាវាយតម្លៃលើបរិមាណផលិតផលថ្នាំជក់ដែលនាំចេញ នាំចូល តម្លៃ និងការប្រើប្រាស់ថ្នាំជក់ វត្ថុធាតុដើម គ្រឿងម៉ាស៊ីន ប្រាក់ចំណូល ការដាំដំណាំថ្នាំជក់ និងព័ត៌មានផ្សេងៗទៀត។

៧. បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

**គ.ត.ផ.ថ.** មានមជ្ឈមណ្ឌលជាតិលើកកំពស់សុខភាពនៃក្រសួងសុខាភិបាលជាលេខាធិការដ្ឋាន ដែលមានភារកិច្ចដូចតទៅ៖

១. រៀបចំនិងធ្វើរបាយការណ៍កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់។

២. ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នដែលមានតំណាងជាសមាជិក **គ.ត.ផ.ថ.**។

៣. បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ **គ.ត.ផ.ថ.**។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ត.ផ.ថ.

**មាត្រា៦ .-**

**គ.ត.ផ.ថ.** ត្រូវធ្វើការប្រជុំយ៉ាងតិចពីរដងក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធាន និងអាចកោះប្រជុំវិសាមញ្ញតាមការចាំបាច់តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានមានធុរៈ ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធានណាម្នាក់ ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៧ .-**

**គ.ត.ផ.ថ.** ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល និងផ្នែកឯកជនដែលគ្មានទំនាក់ទំនងជាមួយឧស្សាហកម្មថ្នាំជក់ ដើម្បីជំរុញកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកនៃការប្រើប្រាស់ផលិតផលថ្នាំជក់។

**មាត្រា៨ .-**

**គ.ត.ផ.ថ.** មានសិទ្ធិប្រើត្រារបស់ក្រសួងសុខាភិបាល ដើម្បីដំណើរការការងាររបស់ខ្លួន។

**មាត្រា៩ .-**

**គ.ត.ផ.ថ.** ត្រូវបង្កើតអនុគណៈកម្មាធិការដែលសរសេរជាអក្សរកាត់ថា "**អ.គ.ត.ផ.ថ.**" នៅតាមរាជធានីខេត្តតាមការចាំបាច់ ដើម្បីជួយបំពេញការងាររបស់ខ្លួន។

**មាត្រា១០ .-**

សមាសភាពនិងតួនាទីរបស់អនុគណៈកម្មាធិការនៅតាមរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ត.ផ.ថ.**។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា១១ .-**

**គ.ត.ផ.ថ.** ត្រូវមានប្រភពធនធានផ្តត់ផ្គង់ដោយថវិកាជាតិសម្រាប់ដំណើរការ។

**គ.ត.ផ.ថ.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីដៃគូអភិវឌ្ឍនិងប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា១២ .-**

ចំពោះអនុគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ដែលត្រូវបង្កើតនៅតាមរាជធានី ខេត្ត មានប្រភពធនធានដែលផ្គត់ផ្គង់ដោយកញ្ចប់ថវិកាជាតិរបស់រាជធានី ខេត្ត សាមី និងមូលនិធិដែលបានមកពីដៃគូអភិវឌ្ឍនិងប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ